# DE INTERNATIONAL
# (អង្គភាពទទួលបន្ទុកនិស្សិតអន្តរជាតិរបស់ក្រសួងអប់រំ)

## ព័ត៌មានសម្រាប់និស្សិតអន្តរជាតិ

ច្បាប់របស់ប្រទេសអូស្ត្រាលីលើកកម្ពស់ការអប់រំប្រកបដោយគុណភាព និងការការពារអ្នកប្រើប្រាស់សម្រាប់សិស្សបរទេស។ ច្បាប់ទាំងនេះត្រូវបានគេស្គាល់ថាជាក្របខ័ណ្ឌ ESOS ហើយរួមមានច្បាប់សេវាកម្មអប់រំសម្រាប់និស្សិតបរទេស ((ESOS) ឆ្នាំ2000 និងក្រមថ្នាក់ជាតិ។ សម្រាប់សេចក្តីសង្ខេបនៃក្របខ័ណ្ឌ ESOS សូមចូលទៅកាន់គេហទំព័រ៖
https://internationaleducation.gov.au/Regulatory-Information/Pages/Regulatoryinformation.aspx

សម្រាប់ព័ត៌មានអំពីលក្ខខណ្ឌតម្រូវទិដ្ឋាការសិស្ស សូមមើលគេហទំព័ររបស់ក្រសួងកិច្ចការផ្ទៃក្នុង (Department of Home Affairs)៖
https://www.homeaffairs.gov.au

សូមទាក់ទងអ្នកសម្របសម្រួលនិស្សិតអន្តរជាតិនៅសាលារៀនរបស់អ្នក ប្រសិនបើអ្នកមានកង្វល់ ឬសំណួរណាមួយអំពីសាលារៀនរបស់អ្នក បញ្ហាផ្ទាល់ខ្លួន ឬបញ្ហាផ្សេងទៀត។ អ្នកសម្របសម្រួលនិស្សិតអន្តរជាតិនឹងជួយអ្នក ឬបញ្ជូនអ្នកទៅកាន់បុគ្គលិកដែលសមស្រប។

បទប្បញ្ញត្តិនានាខាងក្រោមអនុវត្តចំពោះការសិក្សារបស់អ្នកនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW៖

### លក្ខខណ្ឌការចូលរៀន និងវគ្គសិក្សា

- អ្នកត្រូវតែមករៀនយ៉ាងតិច80% នៃថ្នាក់ដែលបានគ្រោងទុកទាំងអស់។ ប្រសិនបើអ្នកមិនបំពេញតាមលក្ខខណ្ឌតម្រូវការមករៀនទេ អ្នកអាចនឹងត្រូវបានរាយការណ៍ទៅក្រសួងអន្តោប្រវេសន៍ លុះត្រាតែអ្នកមានកាលៈទេសៈគួរឱ្យអាណិតអាសូរ ឬគួរទុកចិត្តបាន (គោលការណ៍ណែនាំមានផ្តល់ជូនខាងក្រោម)។
- អ្នកត្រូវតែផ្តល់សំបុត្រពេទ្យសម្រាប់អវត្តមានរយៈពេលបីថ្ងៃ ឬច្រើនជាងនេះ។ វេជ្ជបណ្ឌិតនោះត្រូវតែជាអ្នកអនុវត្តវេជ្ជសាស្ត្រដែលបានចុះឈ្មោះក្នុងបញ្ជីស្របច្បាប់។ ប្រសិនបើអ្នកអវត្តមានមួយ ឬពីរថ្ងៃ អាណាព្យាបាល/អ្នកថែទាំរបស់អ្នកត្រូវផ្តល់លិខិតពន្យល់មួយច្បាប់ ឬប្រសិនបើអ្នកមានអាយុលើសពី18ឆ្នាំ អ្នកអាចផ្តល់ការពន្យល់ជាលាយលក្ខណ៍អក្សរផ្ទាល់ខ្លួនរបស់អ្នក។
- អ្នកត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវវឌ្ឍនភាពវគ្គសិក្សានានា។ សាលារៀនរបស់អ្នក នឹងផ្តល់ឱ្យអ្នកនូវព័ត៌មានអំពីលក្ខខណ្ឌតម្រូវលើវគ្គសិក្សាដូចដែលបានគូសបញ្ជាក់ដោយអាជ្ញាធរស្តង់ដារអប់រំរដ្ឋ NSW (NESA)។ ព័ត៌មានបន្ថែមអំពីលក្ខខណ្ឌតម្រូវលើវគ្គសិក្សា អាចរកបាននៅតាមគេហទំព័រ www.educationstandards.nsw.edu.au
- យុទ្ធសាស្ត្រអន្តរាគមន៍នឹងត្រូវអនុវត្ត ប្រសិនបើអ្នកស្ថិតក្នុងហានិភ័យនៃការមិនបំពេញតាមលក្ខខណ្ឌតម្រូវលើវគ្គសិក្សាជាទីគាប់ចិត្ត។ ប្រសិនបើអ្នកត្រូវបានចាត់ទុកថាមិនទាន់មានសមត្ថភាព50% ឬច្រើនជាងនេះក្នុងអំឡុងពេលសិក្សាណាមួយ អ្នកអាចនឹងត្រូវបានរាយការណ៍ទៅក្រសួងអន្តោប្រវេសន៍។

### ការរៀបចំទីស្នាក់អាស្រ័យ និងសុខុមាលភាព

- សិស្សទាំងអស់ត្រូវតែបានអមដំណើរទៅកាន់ទីស្នាក់អាស្រ័យដែលបានអនុម័ត នៅពេលមកដល់ប្រទេសអូស្ត្រាលី។

  - ប្រសិនបើអ្នកបានស្នើសុំឱ្យរៀបចំគ្រួសារម្ចាស់លំនៅដ្ឋានក្នុងតំបន់ (homestay) មួយសម្រាប់អ្នក នោះយានជំនិះពីព្រលានយន្តហោះជាកាតព្វកិច្ចនឹងត្រូវបានរៀបចំសម្រាប់អ្នក។

  - ប្រសិនបើសាច់ញាតិ ឬមិត្តភក្តិគ្រួសារជិតស្និទ្ធត្រូវបានអនុម័តជាអ្នកថែទាំរបស់អ្នក នោះការរៀបចំត្រូវតែបានធ្វើឡើងដើម្បីឱ្យពួកគេមកជួបអ្នកនៅព្រលានយន្តហោះអន្តរជាតិស៊ីដនីយ។
- ប្រសិនបើអ្នកមានអាយុក្រោម18ឆ្នាំ អ្នកត្រូវតែ**រក្សាការរៀបចំទីស្នាក់អាស្រ័យ ការគាំទ្រ និងសុខុមាលភាពដែលបានអនុម័តរបស់អ្នក។** អ្នកមិនត្រូវផ្លាស់ប្តូរការរៀបចំទាំងនោះ ដោយគ្មានការអនុម័តជាលាយលក្ខណ៍អក្សរជាមុនពី DE International ឡើយ។ សំណើផ្លាស់ប្តូរចំពោះការរៀបចំទាំងនេះ ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរទៅកាន់ DE International និងចុះហត្ថលេខាដោយឪពុកម្តាយរបស់អ្នក។
- ប្រសិនបើអ្នកចង់ផ្លាស់ប្តូរលំនៅដ្ឋានគ្រួសារក្នុងតំបន់របស់អ្នក អ្នកគួរតែទាក់ទងអ្នកសម្របសម្រួលនិស្សិតអន្តរជាតិនៅសាលារៀនរបស់អ្នក។
- ក្រសួងអប់រំរដ្ឋ NSW ណែនាំថាសិស្សដែលមានអាយុលើសពី18ឆ្នាំ បន្តរស់នៅជាមួយសាច់ញាតិ ឬគ្រួសារម្ចាស់លំនៅដ្ឋានក្នុងតំបន់។ ការផ្លាស់ប្តូរទីស្នាក់អាស្រ័យ គួរតែស្ថិតក្នុងចម្ងាយធ្វើដំណើរសមរម្យទៅកាន់សាលារៀនរបស់អ្នក។
- ឪពុកម្តាយ ឬសាច់ញាតិរបស់អ្នក (អ្នកថែទាំដែលបានអនុម័ត) ត្រូវតែជូនដំណឹងដល់សាលារៀនរបស់អ្នក អំពីអាសយដ្ឋានរស់នៅរបស់អ្នកក្នុងរយៈពេលប្រាំពីរថ្ងៃបន្ទាប់ពីការមកដល់ប្រទេសអូស្ត្រាលី ហើយជូនដំណឹងអំពីការផ្លាស់ប្តូរអាសយដ្ឋាន និងព័ត៌មានទំនាក់ទំនងណាមួយក្នុងរយៈពេលប្រាំពីរថ្ងៃ។ សិស្សដែលមានអាយុលើសព18ឆ្នាំ ដែលផ្លាស់ប្តូរអាសយដ្ឋាន ក៏ត្រូវជូនដំណឹងដល់សាលារៀនរបស់ពួកគេផងដែរក្នុងរយៈពេលប្រាំពីរថ្ងៃ។

### លក្ខខណ្ឌនៃការចុះឈ្មោះចូលរៀន

- អ្នកត្រូវតែចាប់ផ្តើមទៅរៀន តាមកាលបរិច្ឆេទចាប់ផ្តើមដែលមានចុះនៅលើ**លិខិតបញ្ជាក់ការចុះឈ្មោះចូលរៀន** ហើយប្រសិនបើមិនអាចធ្វើទៅបានទេ សូមជូនដំណឹងទៅ DE International ជាលាយលក្ខណ៍អក្សរក្នុងរយៈពេល24ម៉ោងគិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើម។
- អ្នកត្រូវតែប្រកាន់ខ្ជាប់នូវវិន័យសាលា និងខបែង និងលក្ខខណ្ឌនៃការចុះឈ្មោះចូលរៀនដែលមានចែងនៅក្នុងទម្រង់ពាក្យសុំសម្រាប់និស្សិតអន្តរជាតិ។ អ្នកនឹងទទួលបានព័ត៌មានអំពីវិន័យសាលា និងអាកប្បកិរិយាដែលត្រូវបានរំពឹងទុកនៅថ្ងៃតម្រង់ទិស។
- សាលារៀនរបស់អ្នកអាចព្យួរ ឬលុបចោលការចុះឈ្មោះចូលរៀនរបស់អ្នក ដោយហេតុផលអាកប្បកិរិយាមិនសមរម្យ។ សម្រាប់ព័ត៌មានបន្ថែមអំពីអាកប្បកិរិយារបស់សិស្ស និងការព្យួរ ហើយនិងការបណ្តេញសិស្សចេញពីសាលា សូមសួរអ្នកសម្របសម្រួលនិស្សិតអន្តរជាតិរបស់អ្នកនៅសាលារៀនរបស់អ្នក។
- ការធ្វើដំណើរក្នុងអំឡុងពេលវិស្សមកាល ក្រៅពីការត្រឡប់ទៅប្រទេសកំណើតរបស់អ្នក ត្រូវបានអនុញ្ញាតលុះត្រាតែអ្នកកំពុងធ្វើដំណើរជាមួយអ្នកថែទាំ ឬសាច់ញាតិរបស់អ្នក ឬដំណើរកម្សាន្តរបស់សាលាដែលបានអនុម័តប៉ុណ្ណោះ។ អ្នកចាំបាច់ត្រូវតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីឪពុកម្តាយរបស់អ្នក និងការអនុម័តពី DE International មុនពេលចេញដំណើរ។
- ប្រសិនបើអ្នកចង់ផ្ទេរទៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW មួយផ្សេងទៀត អ្នកត្រូវតែផ្តល់សំណើជាលាយលក្ខណ៍អក្សរទៅកាន់សាលារៀនរបស់អ្នក ដែលចុះហត្ថលេខាដោយឪពុកម្តាយរបស់អ្នក។
- ប្រសិនបើអ្នកចង់ផ្លាស់ប្តូរអ្នកផ្តល់សេវាកម្ម អ្នកត្រូវតែធ្វើសំណើជាលាយលក្ខណ៍អក្សរទៅកាន់សាលារៀនរបស់អ្នក ដែលចុះហត្ថលេខាដោយឪពុកម្តាយរបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងបទប្បញ្ញត្តិទិដ្ឋាការស្តីពីការផ្លាស់ប្តូរអ្នកផ្តល់សេវាកម្ម សូមចូលទៅកាន់គេហទំព័ររបស់ក្រសួងកិច្ចការផ្ទៃក្នុង និងអ្នកសម្របសម្រួលនិស្សិតអន្តរជាតិនៅសាលារៀនរបស់អ្នក។

## ការឈប់សម្រាក

- ប្រសិនបើអ្នកនឹងត្រូវអវត្តមានមួយសប្តាហ៍ ឬច្រើនជាងនេះក្នុងអំឡុងត្រីមាសសិក្សា ឪពុកម្តាយរបស់អ្នកត្រូវតែស្នើសុំការអនុម័តពីនាយកសាលា និង DE International មុនពេលឈប់សម្រាក។
- អ្នកមិនត្រូវពន្យារពេលថ្ងៃចាប់ផ្តើមចូលរៀនរបស់អ្នក ឬឈប់សម្រាកបន្ថែមដោយគ្មានការអនុម័តពី DE International មុនពេលឈប់សម្រាកឡើយ។ ការអនុម័តត្រូវបានផ្តល់តែលើហេតុផលនានាដែលគួរឱ្យទុកចិត្ត ឬគួរឱ្យអាណិតអាសូរប៉ុណ្ណោះ (សូមមើលគោលការណ៍ណែនាំខាងក្រោម)។

## បណ្តឹងតវ៉ា និងបណ្តឹងសាទុក្ខ

- ក្រសួងអប់រំរដ្ឋ NSW មានដំណើរការបណ្តឹងតវ៉ា និងបណ្តឹងសាទុក្ខដែលអាចរកបាននៅលើគេហទំព័រ។ ប្រសិនបើអ្នកមានបំណងចង់ធ្វើបណ្តឹងតវ៉ា ឬបណ្តឹងសាទុក្ខចំពោះការសម្រេចចិត្តដែលបានធ្វើឡើងទាក់ទងនឹងការចុះឈ្មោះចូលរៀន វឌ្ឍនភាពវគ្គសិក្សា ឬការសម្រេចចិត្តផ្សេងទៀត អ្នកគួរតែទាក់ទងអ្នកសម្របសម្រួលនិស្សិតអន្តរជាតិនៅសាលារៀនរបស់អ្នក។

  អ្នកថែទាំរបស់អ្នក (ប្រសិនបើអ្នកមានអាយុក្រោម18ឆ្នាំ) ឬអ្នកគាំទ្រ (ប្រសិនបើអ្នកមានអាយុលើសពី18ឆ្នាំ) ត្រូវតែមានវត្តមានជាមួយអ្នកនៅក្នុងកិច្ចសម្ភាសន៍ទាក់ទងនឹងបណ្តឹងសាទុក្ខណាមួយ។
- ប្រសិនបើអ្នកមិនពេញចិត្តនឹងលទ្ធផលនៃដំណើរការបណ្តឹងតវ៉ា និងបណ្តឹងសាទុក្ខផ្ទៃក្នុង អ្នកនឹងត្រូវបានណែនាំអំពីរបៀបចូលប្រើប្រាស់ដំណើរការបណ្តឹងតវ៉ាខាងក្រៅតាមរយៈ Ombudsman NSW (អាជ្ញាធរឯករាជ្យដោះស្រាយបណ្តឹងតវ៉ាពីពលរដ្ឋក្នុងរដ្ឋ NSW)។
- អ្នកត្រូវតែបន្តចុះឈ្មោះចូលរៀននៅសាលារបស់អ្នកពេញមួយដំណើរការបណ្តឹងតវ៉ាណាមួយ រហូតដល់ដំណើរការនេះបានបញ្ចប់។

## ការងារ

- ដើម្បីធ្វើការក្រៅម៉ោង DE International តម្រូវថាអ្នកត្រូវតែបានចុះឈ្មោះចូលរៀនយ៉ាងហោចណាស់ប្រាំមួយខែនៅសាលារៀនបច្ចុប្បន្នរបស់អ្នក មានកំណត់ត្រាមករៀនជាទីគាប់ចិត្ត និងផ្តល់ឱ្យសាលារៀនរបស់អ្នកនូវលិខិតយល់ព្រមមួយច្បាប់ពីឪពុកម្តាយរបស់អ្នក មុនពេលចាប់ផ្តើមការងារក្រៅម៉ោង។
- ក្នុងពេលបរវេសនកាល រាល់ការងារក្រៅម៉ោងដែលសិស្សមាន មិនត្រូវអោយប៉ះពាល់ដល់ម៉ោងសិក្សារបស់ពួកគេ ហើយ មិនគួរលើសពី ១0ម៉ោងក្នុងមួយសប្តាហ៍ឡើយ។ តែយ៉ាងណាក្នុងពេលវិស្សមកាល សិស្សអាចធ្វើការក្រៅម៉ោងមិនអោយលើស ៤0 ម៉ោងក្នុងរយៈពេលពីរប្តាហ៍។* *សំរាប់សិស្សបំប៉ន់ភាសាអង់គ្លេស(IEC) មិនត្រូវបានអនុញ្ញាតោយធ្វើការងារទេ។

## គោលការណ៍ណែនាំសម្រាប់កាលៈទេសៈគួរឱ្យអាណិតអាសូរ ឬគួរឱ្យទុកចិត្ត

ការឈប់សម្រាកដែលបានអនុម័តដោយមានកាលៈទេសៈគួរឱ្យអាណិតអាសូរ ឬគួរឱ្យទុកចិត្ត មិនបានរាប់បញ្ចូលក្នុងកំណត់ត្រាមករៀនទេ។ កាលៈទេសៈគួរឱ្យអាណិតអាសូរ ឬគួរឱ្យទុកចិត្ត ជាទូទៅគឺជាស្ថានភាពនានាដែលហួសពីការគ្រប់គ្រងរបស់អ្នក ហើយដែលមានផលប៉ះពាល់ទៅលើវឌ្ឍនភាពសិក្សា ឬសុខុមាលភាពរបស់អ្នក។ ទាំងនេះអាចរួមបញ្ចូល ប៉ុន្តែអាចមានលើសពីនេះ៖

- ជំងឺ ដែលសំបុត្រពេទ្យបញ្ជាក់ថាអ្នកមិនអាចមករៀនបាន ឬ
- ការបាត់បង់សមាជិកគ្រួសារជិតស្និទ្ធ ដូចជាឪពុកម្តាយ ឬជីដូនជីតា (ប្រសិនបើអាចធ្វើទៅបាន គួរតែផ្តល់សំបុត្រមរណៈភាព ឬភស្តុតាងផ្សេងទៀត មុនពេលចេញដំណើរ ឬនៅពេលត្រឡប់មកវិញ) ឬ
- ចលាចលនយោបាយ ឬគ្រោះមហន្តរាយធម្មជាតិដ៏ធំនៅក្នុងប្រទេសកំណើត ដែលទាមទារឱ្យអ្នកធ្វើដំណើរជាបន្ទាន់ ហើយវាមានផលប៉ះពាល់ដល់ការសិក្សារបស់អ្នក ឬ
- បទពិសោធន៍ស្លុតរន្ធត់ដែលអាចរួមបញ្ចូល ប៉ុន្តែអាចមានលើសពីនេះ៖
  - ការទាក់ទិននៅក្នុង ឬការធ្វើជាសាក្សីនៃគ្រោះថ្នាក់មួយ
  - ការធ្វើជាសាក្សី ឬជាជនរងគ្រោះនៃឧក្រិដ្ឋកម្ម
- ហើយវាមានផលប៉ះពាល់មកលើអ្នក (ករណីទាំងនេះគួរតែបានគាំទ្រដោយរបាយការណ៍របស់ប៉ូលីស ឬគ្រូពេទ្យចិត្តសាស្ត្រ ឬជំបូន្មានជាលាយលក្ខណ៍អក្សរពីអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលសមស្របម្នាក់)
- មិនអាចចាប់ផ្តើមសិក្សានៅថ្ងៃចាប់ផ្តើមវគ្គសិក្សា ដោយសារតែការពន្យារពេលក្នុងការទទួលបានទិដ្ឋាការសិស្ស។

## ការពន្យារពេលនៃថ្ងៃចាប់ផ្តើមវគ្គសិក្សា

រាល់សំណើសុំពន្យារពេលការសិក្សាត្រូវដាក់ជូនជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយឪពុកម្តាយរបស់អ្នកទៅកាន់ DE International។ សំណើសុំពន្យារពេលសិក្សាបន្ទាប់ពីទិដ្ឋាការសិស្សរបស់អ្នកត្រូវបានចេញឱ្យនឹងត្រូវបានអនុម័តតែក្នុងលក្ខខណ្ឌ ដែលមានផ្តល់ភស្តុតាងនៃកាលៈទេសៈគួរឱ្យអាណិតអាសូរ ឬគួរឱ្យទុកចិត្ត។ ការពន្យារពេលសិក្សាអាចប៉ះពាល់ដល់ទិដ្ឋាការរបស់អ្នក ដូច្នេះសូមពិគ្រោះយោបល់ជាមួយក្រសួងអន្តោប្រវេសន៍ មុនពេលដាក់សំណើ។

## ការព្យួរការសិក្សា

ប្រសិនបើអ្នកត្រូវបានតម្រូវឱ្យឈប់សម្រាកពីការសិក្សាដោយសារតែកាលៈទេសៈគួរឱ្យអាណិតអាសូរ ឬគួរឱ្យទុកចិត្ត ការព្យួរការសិក្សារបស់អ្នកអាចធ្វើទៅបាន ដោយហេតុនេះអវត្តមានរបស់អ្នកមិនបានរាប់បញ្ចូលក្នុងអត្រាមករៀនរបស់អ្នកទេ។

មុនពេលឈប់សម្រាក សំណើដែលបានចុះហត្ថលេខាពីឪពុកម្តាយរបស់អ្នកត្រូវតែដាក់ជូនទៅ DE International រួមជាមួយនឹងភស្តុតាងនៃកាលៈទេសៈគួរឱ្យអាណិតអាសូរ ឬគួរឱ្យទុកចិត្ត។

ការព្យួរការសិក្សាអាចប៉ះពាល់ដល់ទិដ្ឋាការរបស់អ្នក ដូច្នេះសូមពិគ្រោះយោបល់ជាមួយក្រសួងអន្តោប្រវេសន៍ មុនពេលដាក់សំណើ។

Updated April 2024